# ករណីសិក្សា៖ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវនៅខេត្តតាកែវ[១]

## សេចក្ដីផ្ដើម

នៅអំឡុងឆ្នាំ២០០១-១០ ផលិតកម្មកសិកម្មបានកើនឡើងគួរឲ្យកត់សម្គាល់ ដោយមានអត្រាកំណើនជាមធ្យមប្រហែល ៥%។ ស្រូវជាអនុវិស័យដំណាំធំជាងគេ ដោយមានកំណើនជាមធ្យម ៧,៧% ក្នុងមួយឆ្នាំ និងរួមចំណែក ២៦% ក្នុងផលិតផលក្នុងស្រុកសរុប (ផសស) ខាងកសិកម្ម (NIS 2011)។ ទោះមានការរីកចម្រើនបែបនេះក្ដី ការសិក្សាជាច្រើនបានពិនិត្យឃើញនូវឧបសគ្គក្រោយការប្រមូលផលផ្សេងៗ ដែលជះឥទ្ធិពលទៅលើផលិតភាពវិស័យកសិកម្ម មានជាអាទិ៍ ១) ការខាតបង់កម្រិតខ្ពស់ និងគុណភាពអន់ ដោយសាររបៀបទុកដាក់ផលស្រូវ កន្លែងស្តុកផលស្រូវ ហើយនិង ស្តង់ដារ និងសមត្ថភាពកិនស្រូវ ២) បន្ទុកចំណាយផលិតកម្មខ្ពស់ គួបផ្សំនឹងទិន្នផលទាបក្នុងឆ្នាំខ្លះ ៣) ស្តង់ដារ និងលក្ខណៈក្រៅផ្លូវការនៃពាណិជ្ជកម្មឆ្លងកាត់ព្រំដែនជាមួយថៃ និង វៀតណាម (ACI and CamConsult 2006; RGC 2010; Sok *et al.* 2011)។ ក្ដីបារម្ភដ៏ធំសម្រាប់កសិករដាំស្រូវគឺបន្ទុកចំណាយផលិតកម្មខ្ពស់ ហើយនិងការសម្របសម្រួល និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារអន់ខ្សោយ។

ខេត្តតាកែវមានសក្ដានុពលធំធេង ខាងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន។ ការលក់ស្រូវទៅឲ្យប្រទេសវៀតណាម បានក្លាយជាលក្ខខណ្ឌដ៏សំខាន់បំផុតមួយ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងខេត្ត។ ការសិក្សាពីចំណាយផលិតកម្ម និងខ្សែចង្វាក់តម្លៃទីផ្សារក្នុងខេត្ត អាចជួយបំភ្លឺពីបែបបទនៃការបែងចែកអត្ថប្រយោជន៍ផ្សេងៗក្នុងចំណោមតួអង្គស្ថិតក្នុងខ្សែចង្វាក់នៃតម្លៃ និងពីឧបសគ្គក្រោយការច្រូតកាត់នានា ដែលរារាំងដល់ការអភិវឌ្ឍវិស័យស្រូវនៅកម្ពុជា។ ការសិក្សានេះមានគោលដៅពិនិត្យពីខ្សែចង្វាក់តម្លៃទីផ្សារស្រូវនៅខេត្តតាកែវ និងផ្ដល់មតិពីជម្រើសគោលនយោបាយ ដើម្បីបង្កើន អត្ថប្រយោជន៍ដែលអ្នកដាំស្រូវត្រូវទទួលបាន និងតម្លៃបន្ថែមនៃដំណាំស្រូវនៅកម្ពុជា។ គោលដៅដ៏ជាក់លាក់នានារួមមាន៖ ១) កំណត់ឲ្យច្បាស់នូវខ្សែចង្វាក់តម្លៃនៃដំណាំស្រូវ ២) វិភាគចំណូល ចំណាយ និងអត្រាចំណេញក្នុងផលិតកម្មស្រូវ ៣) ពិនិត្យលើព័ត៌មានទីផ្សារ និងកំណត់ពីទំនាក់ទំនងផ្នែកអភិបាលកិច្ចរវាង សហគ្រាសនានាដែលស្ថិតនៅលំដាប់ជាប់គ្នាក្នុងខ្សែចង្វាក់តម្លៃ និង ៤) កំណត់នូវគោលនយោបាយសមស្របដើម្បីកែលំអការលក់ស្រូវទៅទីផ្សារក្នុងខេត្តតាកែវ។

វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព និងបែបបរិមាណ ដែលអនុវត្តក្នុងការសិក្សាស្ដីពី "ការធ្វើឲ្យខ្សែចង្វាក់តម្លៃ កាន់តែអំណោយផលដល់ជនក្រីក្រ" (M4P 2008) ត្រូវបានយកមកប្រើដើម្បី កំណត់នូវ ខ្សែចង្វាក់តម្លៃ និងរចនាសម្ព័ន្ធសម្របសម្រួលសម្រាប់ដំណាំស្រូវ, យន្តការត្រួតពិនិត្យ, ច្បាប់ និងបទបញ្ញត្តិផ្សេងៗដែលអនុវត្តនៅខេត្តតាកែវ។ ការចុះសិក្សាដល់កន្លែងដើម្បីប្រមូលទិន្នន័យ បានធ្វើឡើងចាប់ពីពាក់កណ្ដាលខែកុម្ភៈដល់ពាក់កណ្ដាលខែមីនា ឆ្នាំ២០១២។ ព័ត៌មានសម្រាប់ការសិក្សានេះក៏ទទួលបានផងដែរតាមរយៈ ការសង្កេតពិនិត្យនៅផ្ទាល់កន្លែង ការពិភាក្សាតាមក្រុមស្នូល និងការសម្ភាសអ្នកផ្ដល់ព័ត៌មានគន្លឹះ ដែលជាតួអង្គស្ថិតក្នុងខ្សែចង្វាក់តម្លៃ គឺមានតាំងពីកសិករ អ្នកប្រមូលទិញស្រូវ ពាណិជ្ជករ រហូតដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ។ ការពិភាក្សាតាមក្រុមស្នូលជាមួយកសិករ បានធ្វើឡើងនៅតាមភូមិនានាក្នុងស្រុក ត្រាំកក់ ព្រៃកប្បាស និងកោះអណ្ដែត។ ព័ត៌មានស្ដីពីការលក់ក៏បានប្រមូលយកនៅក្រុងតាកែវ និង ពីរស្រុកថែមទៀត គឺ អង្គរបុរី និងគិរីវង្ស។ ទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ ទាំងបែបបរិមាណ និងបែបគុណភាព បានយកមកប្រើដើម្បីវិភាគពីតម្លៃបន្ថែមរវាងតួអង្គដែលស្ថិតនៅលំដាប់ជាប់គ្នាក្នុងខ្សែចង្វាក់តម្លៃបន្ថែម។

## លទ្ធផល និងការពិភាក្សា

### *ការកំណត់ខ្សែចង្វាក់តម្លៃ*

ខ្សែចង្វាក់តម្លៃស្រូវ មានពីរ គឺវដ្ដវស្សា និង វដ្ដប្រាំង។ កសិករភាគច្រើនដាំស្រូវវស្សាជាចម្បង សម្រាប់ការប្រើប្រាស់ក្នុងផ្ទះ។ កសិករមួយចំនួនតូចដែលដាំស្រូវប្រាំង តែងមានគោលបំណងសំខាន់ដើម្បីធ្វើពាណិជ្ជកម្ម។ តួអង្គទាំងអស់ក្នុងខ្សែចង្វាក់តម្លៃស្រូវប្រាំងគឺសកម្មខ្លាំង រីឯតួអង្គក្នុងខ្សែចង្វាក់តម្លៃវដ្ដវស្សាមិនសូវសកម្មទេ។ អ្នកប្រមូលទិញស្រូវ និងពាណិជ្ជករតាមភូមិ ជាតួអង្គសំខាន់នៅក្នុងខ្សែចង្វាក់តម្លៃទាំងពីរ (រូបភាព ១) និងជាសហគ្រាសធុនតូចដែលមានសមត្ថភាពទិញស្រូវត្រឹម ១០ ទៅ ៣០តោន ដោយសារកង្វះខាតមធ្យោបាយដឹកជញ្ជូន និងដើមទុន។ ពួកគេទិញស្រូវផ្សេងៗមកលាយចូលគ្នា ប៉ុន្តែបែងចែកប្រភេទស្រូវគុណភាពខ្ពស់ ទុកលក់ក្នុងថ្លៃខ្ពស់ទៅឲ្យពាណិជ្ជករក្នុងតំបន់។ ជាទូទៅ អ្នកប្រមូលទិញស្រូវ និងពាណិជ្ជករក្នុងភូមិ គឺជាកសិកររស់នៅក្នុងភូមិដែលប្រើដើមទុនរបស់ពាណិជ្ជករកម្រិតតំបន់ សម្រាប់យកទៅប្រមូលទិញស្រូវពីកសិករដទៃទៀត ហើយផ្គត់ផ្គង់ទៅឲ្យពាណិជ្ជករតំបន់ ដើម្បីយកប្រាក់កម្រៃជើងសារ ០,០៥ដុល្លារ/បាវ៥០គីឡូ ឬប្រើមូលធនផ្ទាល់ខ្លួនដើម្បីទិញ និងលក់ស្រូវយកចំណេញ។

### *ចំណាយផលិតកម្ម អត្រាចំណេញដុល និង ផលត្រឡប់លើចំណាយសុទ្ធគិតក្នុងមួយថ្ងៃពលកម្មម្ចាស់កសិដ្ឋាន[២]*

កសិករដាំស្រូវនៅក្នុងតំបន់សិក្សា ត្រូវប្រឈមមុខនឹងចំណាយខ្ពស់ទៅលើ ការជួលពលករ និងគ្រឿងម៉ាស៊ីន (សម្រាប់ការ

---

[១] រៀបរៀងដោយលោក ឈឹម ឈន់ ជាអ្នកស្រាវជ្រាវ, បណ្ឌិត ថេង វុទ្ធី ជាអ្នកស្រាវជ្រាវ និង លោក នូ កែវសុទ្ធា ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៅ CDRI ។ អត្ថបទនេះផ្អែកលើ ករណីសិក្សាពីខ្សែចង្វាក់តម្លៃបន្ថែមនៃទីផ្សារស្រូវ សម្រាប់គម្រោងទ្រទ្រង់ដោយ ACIAR (ASEM/2009/023) ស្ដីពី "ការអភិវឌ្ឍគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅឡាវ និងកម្ពុជា" ដែលគ្រោងចប់រួចរាល់នៅខែឧសភា ២០១៤។

[២] ផលត្រឡប់លើចំណាយសុទ្ធគិតក្នុងមួយថ្ងៃពលកម្មម្ចាស់កសិដ្ឋាន=(ទិន្នផល-ចំណាយផ្សេងៗ និងថ្លៃឈ្នួល(មនុស្ស សត្វ សម្ភារៈ)) / ចំនួនថ្ងៃធ្វើការរបស់ម្ចាស់កសិដ្ឋាន។

រូបភាព ១៖ ផែនទី និង លំដាប់លំដោយនៃតួអង្គក្នុងខ្សែចង្វាក់តម្លៃស្រូវនៅខេត្តតាកែវ




រៀបចំដី), ជី, ថ្នាំសម្លាប់សត្វចង្រៃ (សម្រាប់ស្រូវប្រាំង), គ្រាប់ពូជ, និងទឹកស្រោចស្រព (រូបភាព ២ និង ៣)។ ចំណាយលើពលកម្មមានច្រើនដល់ប្រហែល ៣០% នៃចំណាយផលិតកម្មសរុប ឬ ១៥% នៃតម្លៃផលស្រូវវស្សាប្រមូលបានសរុប (តារាង ១)។ កសិករដាំស្រូវវស្សា ភាគច្រើនដាំដុះតាមបែបប្រពៃណី ដែលត្រូវចំណាយច្រើនបំផុតទៅលើការជួលពលកម្ម ជាពិសេសសម្រាប់ការដកស្ទូងដែលត្រូវប្រើពលកម្មច្រើនជាង បើធៀបនឹងស្រូវពង្រោះដែលសមាជិកគ្រួសារតែងធ្វើការដោយខ្លួនឯង។ រីឯកសិករដាំស្រូវប្រាំងវិញ គាត់ប្រើប្រព័ន្ធដាំដុះអតិផល ដែលក្នុងនោះការដាំស្រូវពង្រោះ និងការប្រើគ្រឿងម៉ាស៊ីន បានកាត់បន្ថយដល់សូន្យនូវចំណាយលើការជួលកម្លាំងពលកម្ម។

ថ្លៃទឹកសម្រាប់ការដាំដុះនៅរដូវវស្សា មានចំណែក ២៥% នៃចំណាយផលិតកម្ម ឬ ១៣% នៃតម្លៃផលស្រូវប្រមូលបាន រីឯថ្លៃទឹកសម្រាប់ការដាំដុះនៅរដូវប្រាំង មានចំណែក ១៩% នៃចំណាយផលិតកម្ម ឬ ១១% នៃតម្លៃផលស្រូវប្រមូលបាន[៣]។ ថ្លៃទឹកប្រើប្រាស់ជាចំណាយខ្ពស់បំផុតមួយដែលកសិករ ជាពិសេសកសិករដាំស្រូវប្រាំង តែងត្អូញត្អែរច្រើនជាងគេ។

កសិករធ្វើស្រែប្រាំងចំណាយធំបំផុតលើ ជីគីមី ដែលមាន

[៣] កសិករដាំស្រូវវស្សាចំណាយលើការប្រើទឹកច្រើនជាងកសិករស្រូវប្រាំង ព្រោះមានការរាំងស្ងួតមួយរយៈពេលខ្លីក្នុងរដូវដាំដុះឆ្នាំ២០១១ ហើយគាត់ត្រូវចំណាយជួលម៉ាស៊ីនបូមទឹក និងទិញប្រេងឥន្ធនៈ ដើម្បីបូមទឹកស្រោចស្រពស្រូវគាត់។

រូបភាព ២៖ ចំណាយដាំដុះនៅរដូវវស្សា (ក្នុងមួយហិកតា)




រូបភាព ៣៖ ចំណាយដាំដុះនៅរដូវប្រាំង (ក្នុងមួយហិកតា)




ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើការធ្វើសម្ភាសន៍ដល់កន្លែង អនុវត្តក្នុងខែឧសភា ២០១២

ចំណែកជាមធ្យម ២៣% នៃចំណូលបានពីផលស្រូវសរុប រីឯកសិករធ្វើស្រែវស្សាចំណាយទិញជីតិចជាងនេះច្រើន ត្រឹមប្រហែល ១១% នៃចំណូលបានពីផលស្រូវសរុប (តារាង ១)។ ចំពោះបរិមាណជីប្រើប្រាស់វិញ កសិករប្រាប់ថា គាត់អនុវត្តតាមការណែនាំរបស់អ្នកលក់ជី ឬអ្នកជិតខាង។ កសិករឯទៀត ជាពិសេសអ្នកធ្វើស្រែប្រាំងបានប្រាប់ថា គាត់ដាក់ជីទៅតាមលទ្ធភាពអាចធ្វើបាន ដើម្បីទទួលបានទិន្នផលខ្ពស់។

ការទិញថ្នាំសម្លាប់សត្វចង្រៃជាចំណាយធំមួយទៀត ជាពិសេសសម្រាប់កសិករធ្វើស្រែប្រាំង។ ជាទូទៅ កសិករធ្វើស្រែវស្សាមិនប្រើថ្នាំសម្លាប់សត្វចង្រៃទេ លើកលែងតែមានសត្វចង្រៃរាតត្បាតខ្លាំងពេក។

កសិករធ្វើស្រែវស្សាតែងទុកស្រូវបានពីស្រែរបស់ខ្លួនសម្រាប់ធ្វើពូជ ហើយចូលចិត្តប្រើស្រូវពូជរបស់ខ្លួនឯង ព្រោះគាត់មានលទ្ធភាពតែប៉ុណ្ណេះ។ ប៉ុន្តែកសិករធ្វើស្រែប្រាំងតែងទិញគ្រាប់ពូជមានថ្លៃខ្ពស់គួរសម ប្រហែលជា ៦% នៃតម្លៃផលស្រូវប្រមូលបាន (តារាង ១)។

ជាមធ្យម ស្រូវវស្សាផ្តល់ទិន្នផល ២,៣តោន/ហិកតា ហើយស្រូវប្រាំងផ្តល់ប្រហែល ៧,២តោន/ហិកតា។ ថ្លៃលក់ស្រូវនៅកន្លែងកសិដ្ឋាន គឺប្រហែល ២៥០ដុល្លារ/តោន សម្រាប់ស្រូវវស្សា និង ១៩៤ដុល្លារ/តោន សម្រាប់ស្រូវប្រាំង។ ថ្លៃលក់ស្រូវវស្សានៅតាមកសិដ្ឋានស្រង់បានពីការចុះសម្ភាសដល់កន្លែងកាលពីខែមីនា ២០១២ វាស្រដៀងគ្នានឹងថ្លៃស្រង់បានសម្រាប់ខែតុលា ២០១១ ដែរ (RGC 2011)។ ចំណូលដុលបានពីកសិដ្ឋានជាមធ្យម គឺ ៥៧៥ដុល្លារ សម្រាប់ស្រូវវស្សា និង ១៣៩៦ដុល្លារ សម្រាប់ស្រូវប្រាំង (តារាង ១)។ ចំណាយផលិតកម្មទាំងសម្រាប់ស្រូវវស្សា និងស្រូវប្រាំង វាខ្ពស់ជាខ្លាំង ហើយភាគច្រើនស្ថិតនៅក្រៅលទ្ធភាពគ្រប់គ្រងរបស់កសិករ ដែលធ្វើឲ្យប្រាក់ចំណេញដុលមានកម្រិតទាបសម្រាប់ផលិតកម្មស្រូវទាំងពីររដូវ។

## ការវិភាគពីខ្សែចង្វាក់តម្លៃ

រចនាសម្ព័ន្ធទីផ្សារបានរៀបចំឡើងយ៉ាងល្អ ដោយមានបណ្តាញអ្នកប្រមូលទិញ ពាណិជ្ជករ អ្នកនាំចេញ រោងម៉ាស៊ីនកិនស្រូវ និងពាណិជ្ជករអន្តរជាតិ (រូបភាព ១)។ ទីផ្សារស្រូវមានប្រសិទ្ធភាពខ្ពស់ ដោយមានតួអង្គច្រើនរួមចំណែក និងការប្រកួតប្រជែងខ្លាំងតាមថ្លៃកំណត់ដោយកម្លាំងទីផ្សារ។ កសិករអាចលក់ស្រូវតាំងពីដើមឆ្នាំដល់ចុងឆ្នាំ ក្នុងទីផ្សារមានការប្រកួតប្រជែងខ្ពស់។ ព័ត៌មានអំពីថ្លៃតាមប្រភេទ និងគុណភាពស្រូវ មានធ្វើបច្ចុប្បន្នភាពស្ទើររាល់ថ្ងៃ ដែលបង្ហាញពីការប្រកួតប្រជែងខ្លាំង ដើម្បីបានប្រាក់ចំណេញ រវាងតួអង្គនៅក្នុងខ្សែចង្វាក់តម្លៃស្រូវ (Gergely *et al.* 2010)។

តារាង ៣ និង ៤ បង្ហាញពីមុខចំណាយលំអិត និងអត្រាចំណេញនៅក្នុងខ្សែចង្វាក់តម្លៃស្រូវ។ តម្លៃបន្ថែមរវាងតួអង្គស្ថិតនៅលំដាប់ជាប់គ្នាក្នុងខ្សែចង្វាក់តម្លៃ ត្រូវបានគណនាឡើងដោយផ្អែកលើព័ត៌មានអំពីថ្លៃទិញថ្លៃលក់ ប្រព័ន្ធផ្គត់ផ្គង់ ចំណាយដឹកជញ្ជូន និងអត្រាចំណេញ ដែលប្រមូលបាននៅពេលចុះសម្ភាសដល់កន្លែង ពីខែកុម្ភៈ ដល់ មីនា ២០១២។

កសិករធ្វើស្រែវស្សាភាគច្រើន លក់ស្រូវជាលក្ខណៈបុគ្គលទៅឲ្យអ្នកប្រមូលទិញតាមភូមិដោយគិតតាមថ្លៃទិញដល់កសិដ្ឋាន

តារាង១៖ ការវិភាគពីចំណេញដុលសម្រាប់ការដាំស្រូវ (ក្នុងមួយហិកតា)

| សកម្មភាព | រដូវវស្សា | | រដូវប្រាំង | |
|---|---|---|---|---|
| | ដុល្លារ | % | ដុល្លារ | % |
| ធាតុចេញ៖ ផលស្រូវ | 575 | 100 | 1396 | 100 |
| ធាតុចូល | | | | |
| ការរៀបចំដី | 40 | 7 | 90 | 6 |
| គ្រាប់ពូជ | 19 | 3 | 90 | 6 |
| ថ្លៃឈ្នួលពលកម្ម | 88 | 15 | 0 | 0 |
| ជីគីមី | 61 | 11 | 321 | 23 |
| ថ្នាំសម្លាប់សត្វចង្រៃ | 0 | 0 | 125 | 9 |
| ទឹកស្រោចស្រព | 75 | 13 | 160 | 11 |
| ការបោកបែន | 15 | 3 | 70 | 5 |
| ចំណាយធាតុចូលសរុប | 298 | 52 | 856 | 61 |
| ចំណេញដុល មិនគិតចូលនូវពលកម្មក្នុងគ្រួសារ | 277 | 48 | 540 | 39 |
| ចំណេញដុល មានគិតចូលនូវពលកម្មក្នុងគ្រួសារ | 150 | 26 | 297 | 21 |
| ផលត្រឡប់គិតក្នុងមួយថ្ងៃពលកម្មម្ចាស់កសិដ្ឋាន | 8.15 | | 8.31 | |
| ចំណាយ (ក្នុងមួយគីឡូក្រាម) | 0.13 | | 0.12 | |
| ចំណេញ (ក្នុងមួយគីឡូក្រាម) | 0.12 | | 0.07 | |

កំណត់សម្គាល់៖ អត្រាប្តូរប្រាក់ ១ដុល្លារ= ៤០០០រៀល។

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើការចុះសម្ភាសដល់កន្លែង នៅខែឧសភា ២០១២

តារាង ២៖ ថ្លៃស្រូវនៅកម្ពុជា (ដុល្លារ/តោន) ពីខែសីហា ២០១១ ដល់ តុលា ២០១១

| | កម្ពុជា | ថៃ | វៀតណាម | ការខុសថ្លៃគ្នា | |
|---|---|---|---|---|---|
| | | | | ថៃ | វៀតណាម |
| **ស្រូវអង្ករធម្មតា** | | | | | |
| ថ្លៃនៅកសិដ្ឋាន | 250-350 | 340-350 | 340-350 | 90-0 | 90-0 |
| អង្ករកិនរួច | 650 | 490-493 | 461 | 157-160 | 89 |
| ថ្លៃនាំចេញ (FOB) | 680 | 605-610 | 565-575 | 70-75 | 105-115 |
| **ស្រូវអង្ករក្រអូប** | | | | | |
| ថ្លៃនៅកសិដ្ឋាន | 354-452 | 402-452 | - | 47-0 | - |
| អង្ករកិនរួច | 870 | 907-910 | - | 37-40 | - |
| ថ្លៃនាំចេញ (FOB) | 900 | 1075-1085 | 675-685 | 175-185 | 185-225 |

សម្គាល់៖ FOB = ថ្លៃទំនិញដឹកដល់លើនាវា

ប្រភព៖ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១១

ប្រហែល ០,២៥ដុល្លារ/គីឡូក្រាម (២៥០ដុល្លារ/តោន)។ អ្នកប្រមូលទិញតាមភូមិត្រូវចេញថ្លៃលើកដាក់ស្រូវ សម្ភារៈផ្ទុកស្រូវ (បាវ, ខ្សែ, ធុង) និងថ្លៃដឹកជញ្ជូន ដែលសរុបមកអស់ប្រហែល ៣,៤ដុល្លារ ឬ ១,៤% នៃថ្លៃស្រូវទិញដល់កសិដ្ឋានសម្រាប់ស្រូវវស្សាប្រភេទចម្រុះ។ ពួកគេតម្លើងថ្លៃស្រូវប្រហែល ៣,៦% ឬស្មើនឹង អប្បហារ ៩ដុល្លារ/តោន ដែលធ្វើឲ្យតម្លៃស្រូវសម្រាប់អ្នកប្រមូលទិញឡើងដល់ ២៦៣ដុល្លារ/តោន។ អប្បហារ ២២% (៥៥ដុល្លារ/តោន) យកដោយពាណិជ្ជករតាមភូមិ វាមានកម្រិតខ្ពស់បើធៀបនឹង អប្បហារ ១៦% (៤០ដុល្លារ/តោន) យកដោយពាណិជ្ជករថ្នាក់តំបន់ ខណៈដែលពាណិជ្ជករតាមភូមិត្រូវចំណាយលើការផ្គត់ផ្គង់ និងដឹកជញ្ជូន (៧,៥ដុល្លារ/តោន) អស់តិចជាង ពាណិជ្ជករតាមតំបន់ (១០ដុល្លារ/តោន)។ នៅពេលទៅដល់រោងកិនស្រូវ ស្រូវឡើងថ្លៃដល់ ៣៧៧ដុល្លារ/តោន ឬកើន ៥០% ធៀបនឹងថ្លៃទិញស្រូវដល់កសិដ្ឋាន (២៥០ដុល្លារ/តោន)។

ខុសប្លែកពីកសិករធ្វើស្រែវស្សា កសិករធ្វើស្រែប្រាំងដាំស្រូវសម្រាប់គោលដៅពាណិជ្ជកម្ម ដូច្នេះ តួអង្គក្នុងខ្សែចង្វាក់តម្លៃស្រូវប្រាំងគាត់សកម្មជាខ្លាំង ឯការជួញដូរក៏មានការប្រកួតប្រជែងខ្លាំងដែរ។ ស្រូវលក់ដូរនៅរដូវប្រាំង ភាគច្រើនប្រើពូជ IR ដែលផ្តល់ស្រូវមានគុណភាពអន់ជាងពូជស្រូវវស្សា ហើយថ្លៃលក់នៅកសិដ្ឋានក៏ទាបជាងដែរ ប្រហែល ១៩៣ដុល្លារ/តោន (តារាង ៤)។ ដូចស្រូវវស្សាដែរ តម្លៃបន្ថែមលើថ្លៃលក់ដូរនៅកសិដ្ឋានកើតមានឡើងដោយសារចំណាយលើការលើកដាក់ ដឹកជញ្ជូន និងកម្រៃក្រៅផ្លូវការ។ ប៉ុន្តែកម្រិតអប្បហាររវាងតួអង្គស្ថិតនៅក្នុងខ្សែចង្វាក់តម្លៃ មិនសូវប្រែប្រួលខ្លាំងដូចក្នុងខ្សែចង្វាក់តម្លៃស្រូវវស្សាទេ គឺត្រឹម ៣,៤% ទៅ ៧,៥% ឬ ប្រហែល ៧ដុល្លារ ទៅ ១៤ដុល្លារ/តោន។ ចំណុចនេះបង្ហាញថា ទីផ្សារស្រូវប្រាំងមានប្រសិទ្ធភាព និងការប្រកួតប្រជែងខ្លាំងជាងក្នុងចំណោមតួអង្គនានា ហើយក៏មានព័ត៌មានថ្មីៗជាប់រហូតអំពីថ្លៃស្រូវដែរ។

### ទំនាក់ទំនង អភិបាលកិច្ច និងបញ្ហាប្រឈមក្នុងខ្សែចង្វាក់តម្លៃទីផ្សារស្រូវ

រូបភាព ៤ បង្ហាញពីការសម្របសម្រួល និងដំណើរការផ្លាស់ប្តូរព័ត៌មានគ្នាក្នុងខ្សែចង្វាក់តម្លៃស្រូវ នៅខេត្តតាកែវ។ ពាណិជ្ជករវៀតណាមកំណត់ថ្លៃ គុណភាព និងបរិមាណស្រូវ ហើយកសិករជាអ្នកទទួលយកថ្លៃនោះ។ ពាណិជ្ជករកម្ពុជា មានអំណាច

តារាង ៣៖ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវវស្សា (ដុល្លារ/តោន)

| | អ្នកប្រមូលទិញតាមភូមិ | | ពាណិជ្ជករក្នុងភូមិ/មូលដ្ឋាន | | ពាណិជ្ជករកម្រិតតំបន់ | | ម្ចាស់រោងកិនស្រូវខេត្ត | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារ | % | ដុល្លារ | % | ដុល្លារ | % | ដុល្លារ | % |
| ទិញចូល | 250.0 | 100.0 | 262.5 | 105.0 | 325.0 | 130.0 | 375.0 | 150.0 |
| លើកដាក់ស្រូវ | 1.0 | 0.4 | 2.0 | 0.8 | 2.0 | 0.8 | 2.0 | 0.8 |
| ដឹកជញ្ជូន | 1.4 | 0.6 | 4.1 | 1.6 | 5.0 | 2.0 | 0.0 | 0.0 |
| សម្ភារៈ | 1.0 | 0.4 | 1.5 | 0.6 | 1.5 | 0.6 | 0.0 | 0.0 |
| កម្រៃក្រៅផ្លូវការ | 0.0 | 0.0 | 0.0 | 0.0 | 1.5 | 0.6 | 0.0 | 0.0 |
| អប្បហារ | 9.1 | 3.6 | 54.9 | 22.0 | 40.0 | 16.0 | 0.0 | 0.0 |
| **សរុប** | **262.5** | **105.0** | **325.0** | **130.0** | **375.0** | **150.0** | **377.0** | **150.8** |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យបានពីការសម្ភាសដល់កន្លែង ខែឧសភា ២០១២

តារាង ៤៖ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវវស្សា (ដុល្លារ/តោន)

| | អ្នកប្រមូលទិញតាមភូមិ | | ពាណិជ្ជករក្នុងភូមិ/មូលដ្ឋាន | | ពាណិជ្ជករថ្នាក់តំបន់ | | អ្នកនាំចេញ | | ពាណិជ្ជករវៀតណាម | |
|---|---|---|---|---|---|---|---|---|---|---|
| | USD | % | USD | % | USD | % | USD | % | USD | % |
| ទិញចូល | 192.5 | 100.0 | 202.5 | 105.2 | 217.5 | 113.0 | 237.5 | 123.4 | 262.5 | 136.4 |
| លើកដាក់ស្រូវ | 1.0 | 0.5 | 2.0 | 1.0 | 2.0 | 1.0 | 2.0 | 1.0 | 2.0 | 1.0 |
| ដឹកជញ្ជូន | 1.4 | 0.7 | 4.1 | 2.1 | 5.0 | 2.6 | 5.0 | 2.6 | 0.0 | 0.0 |
| សម្ភារៈ | 1.0 | 0.5 | 1.5 | 0.8 | 1.5 | 0.8 | 1.5 | 0.8 | 0.0 | 0.0 |
| កម្រៃក្រៅផ្លូវការ | 0.0 | 0.0 | 0.0 | 0.0 | 1.5 | 0.8 | 2.0 | 1.0 | 0.0 | 0.0 |
| អប្បហារ | 6.6 | 3.4 | 7.4 | 3.8 | 10.0 | 5.2 | 14.5 | 7.5 | 0.0 | 0.0 |
| **សរុប** | **202.5** | **105.1** | **217.5** | **112.9** | **237.5** | **123.4** | **262.5** | **136.3** | **264.5** | **137.4** |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យបានពីការសម្ភាសដល់កន្លែង ខែឧសភា ២០១២

តិចតួចក្នុងការចរចាពីថ្លៃ និងគុណភាពស្រូវជាមួយពាណិជ្ជករវៀតណាម។ គុណភាពហាក់មិនមែនជាបញ្ហាធំដុំទេនៅពេលមានតម្រូវការខ្ពស់ ប៉ុន្តែជារឿយៗពាណិជ្ជករវៀតណាមបានយកប្រៀប និងបន្ទាបគុណភាពដើម្បីបញ្ចុះថ្លៃស្រូវ។

នាបច្ចុប្បន្ន មិនទាន់មានយន្តការត្រួតពិនិត្យគុណភាពជាលក្ខណៈប្រព័ន្ធ ឬផ្លូវការណាមួយសម្រាប់ធ្វើចំណាត់ថ្នាក់គុណភាពស្រូវនៅតាមដំណាក់កាលនីមួយៗនៃខ្សែចង្វាក់តម្លៃទេ។ តួអង្គនានាត្រូវធ្វើការវាយតម្លៃគុណភាពស្រូវដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍របស់ខ្លួន ហើយលក្ខណៈវិនិច្ឆ័យចម្បង គឺបរិមាណសំណើម និងភាពផ្អូរនៃស្រូវ។

## *គោលនយោបាយស្រូវ*

តាកែវជាខេត្តផលិតស្រូវចម្បងមួយនៅកម្ពុជា ដោយរួមចំណែក ១២,៥% នៃផលិតកម្មស្រូវទូទាំងប្រទេស និង ១៧,៦% នៃអតិរេកស្រូវសរុប ពោលគឺជាខេត្តដ៏សំខាន់មួយសម្រាប់សម្រេចគោលនយោបាយ "មាសស" របស់រដ្ឋាភិបាលដែលសំដៅនាំចេញស្រូវឲ្យបាន ១លានតោន នៅក្នុងឆ្នាំ២០១៥។ ទោះបីខេត្តតាកែវមានសក្តានុពលខ្ពស់ដើម្បីផលិតអតិរេកស្រូវសម្រាប់ការនាំចេញក្តី ក៏នៅមានចំណុចខ្វះខាតជាច្រើន ដូចជា ពូជមានគុណភាពអន់ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅមានកម្រិត និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់សម្រាប់ទិញលក់ស្រូវ ក្រោយពេលប្រមូលផល។

**ពូជស្រូវ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំឲ្យប្រើនិងជំរុញពូជស្រូវ១០មុខក្នុងនេះមានទាំងស្រូវស្រាលបីមុខ គឺសែនពិដោរ, IR66 និង ជលសារ ដែលមានសក្តានុពលក្នុងការផលិតស្រូវឲ្យបានស្របតាមស្តង់ដារនាំចេញ។ ទោះយ៉ាងនេះក្តី កសិករនៅតែបន្តប្រើពូជស្រូវ IR504 មកពីវៀតណាម ជាជាងពូជស្រូវក្នុងស្រុកដែលក្រសួងកសិកម្ម បានជំរុញសម្រាប់ទីផ្សារនាំចេញ។ ពូជស្រូវ IR504 មានប្រើយ៉ាងទូលំទូលាយក្នុងតំបន់មានប្រព័ន្ធស្រោចស្រព និងតំបន់ធ្វើស្រូវប្រដេញទឹក ដោយមានចំណែកប្រហែល ៤១% នៃផលិតកម្មស្រូវសរុបនៅខេត្តតាកែវ។ ទោះបីនៅទីផ្សារក្នុងស្រុកគេចាត់ទុកថា ពូជស្រូវនេះមានគុណភាពអន់ក្តី ប៉ុន្តែទិន្នផលខ្ពស់ និងតម្រូវការខ្ពស់ពីពាណិជ្ជករវៀតណាម បានជំរុញកសិករឲ្យដាំស្រូវប្រភេទនេះជាលក្ខណៈពាណិជ្ជកម្ម ។

**ពូជគុណភាពអន់៖** កសិករនៅតែបន្តប្រើគ្រាប់ពូជគុណភាពអន់។ ទោះបីមានការរីកចម្រើនខាងជំនាញឯកទេសក្តី ក៏ការផ្គត់ផ្គង់គ្រាប់ពូជ នៅតែមិនទាន់បានគ្រប់គ្រាន់នៅតាមតំបន់ជាច្រើននៅកម្ពុជា ក្នុងនេះមានទាំងខេត្តតាកែវផង។ កសិករភាគច្រើនមិនបានប្តូរគ្រាប់ពូជជាថ្មីឲ្យបានទៀងទាត់ទេ ហើយរបៀបទុកដាក់គ្រាប់ពូជមិនល្អបានធ្វើឲ្យវាលាយឡំចូលគ្នា និងថយចុះអត្រាដុះលូតលាស់ និងគុណភាពជាពូជសុទ្ធ ពីមួយរដូវទៅមួយរដូវ។ កសិករ (ជាពិសេសកសិករធ្វើស្រែវស្សា) តែងផ្លាស់ប្តូរគ្រាប់ពូជ តែក្រោយពេលអ្នកប្រមូលទិញ និងម្ចាស់រោងកិនស្រូវទាមទារនូវស្រូវមានគុណភាពល្អជាងមុន ឬ ដើម្បីទទួលបានថ្លៃខ្ពស់សម្រាប់ផលស្រូវរបស់ខ្លួន។

**កង្វះសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម៖** កសិករត្អូញត្អែរពីបញ្ហាលទ្ធភាពទទួលបានជំនួយបច្ចេកទេស ពីអាជ្ញាធរមូលដ្ឋានដើម្បីគ្រប់គ្រងលើបញ្ហាសត្វចង្រៃជាពិសេសនៅរដូវប្រាំង។ពួកគេមានប្រើថ្នាំសម្លាប់សត្វចង្រៃជាច្រើនប្រភេទ ប៉ុន្តែថ្នាំទាំងនោះខ្លះជាទំនិញហាមឃាត់ និងប៉ះពាល់អាក្រក់ដល់សុខភាព និងបរិស្ថាន។ ថ្នាំសម្លាប់សត្វចង្រៃលក់លើទីផ្សារ ភាគច្រើននាំចូលពីវៀតណាម ឬ ថៃ និងមានសេចក្តីណែនាំពីរបៀបប្រើសរសេរជាភាសាវៀតណាម ឬថៃ ហើយកសិករមិនអាចមើលយល់ពីរបៀបត្រូវប្រុងប្រយ័ត្ន ឬរបៀបលាយនិងប្រើប្រាស់ថ្នាំទាំងនោះទេ។ កង្វះសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការណែនាំពីវិធីប្រើជី ធ្វើឲ្យកសិករត្រូវពឹងផ្អែកលើការណែនាំរបស់ឈ្មួញ ឬក៏ ប្រើជីទៅតាមកម្រិត/បរិមាណ ដែលគាត់មានលទ្ធភាពរកបាន។ ការត្រួតពិនិត្យអន់ខ្សោយនៅតាមច្រកព្រំដែន បានបើកផ្លូវឲ្យជីគ្មានស្តង់ដារហូរចូលមកក្នុងទីផ្សារ។លើសពីនេះទៀតប្រហែល១០% នៃជីលក់លើទីផ្សារជាជីមានការលាយបន្លំ ឬមានគុណភាពទាបដែលគេបានវេចខ្ចប់ជាថ្មី ដោយប្រើបាវមានដាក់ផ្លាកសញ្ញានៃជីគុណភាពខ្ពស់ៗ (Theng 2012)។

**ទីផ្សារស្រូវ៖** ប្រហែល ៦៩% (៧៦៤.៩០២តោន) នៃ

រូបភាព ៤៖ ការសម្របសម្រួលផ្តល់ព័ត៌មានក្នុងខ្សែចង្វាក់តម្លៃ




ផលិតកម្មស្រូវសរុបនៅខេត្តតាកែវ ជាអតិរេកស្រូវ ដែលបង្ហាញពីសក្តានុពលដ៏ធំសម្រាប់ការនាំចេញ។ ប៉ុន្តែកង្វះវិនិយោគជាមូលធនទៅលើរោងកិនស្រូវ និងបច្ចេកវិទ្យាកិនស្រូវទំនើបៗ បានកាត់បន្ថយសមត្ថភាពកែច្នៃអតិរេកស្រូវនេះ ធ្វើឲ្យស្រូវមួយភាគធំត្រូវបាននាំចេញ ជាពិសេសទៅកាន់ប្រទេសវៀតណាម។ ពាណិជ្ជករវៀតណាម ហាក់ដូចអាចគ្របដណ្តប់បានលើពាណិជ្ជកម្មស្រូវនេះ ដោយពួកគេជាអ្នកកំណត់ថ្លៃ និងស្តង់ដាគុណភាព ហើយក៏អាចឆ្លៀតឱកាសបន្ទាបគុណភាព និងបញ្ចុះថ្លៃស្រូវ។ ដូច្នេះ កម្ពុជាចាំបាច់ត្រូវចាត់វិធានការដើម្បីធ្វើចំណាត់ថ្នាក់គុណភាពស្រូវ ដែលអាចធ្វើឲ្យពាណិជ្ជកម្មមានលក្ខណៈយុត្តិធម៌សម្រាប់ភាគីទាំងសងខាង។

## ការពាក់ព័ន្ធដល់គោលនយោបាយ

កសិករត្រូវប្រឈមមុខនឹងចំណាយផលិតកម្មខ្ពស់ និងថ្លៃទិញលក់ទាបៗនៅកសិដ្ឋាន។ ចំណុចនេះបង្ហាញពីតម្រូវការកាត់បន្ថយចំណាយផលិតកម្ម ជាពិសេសចំណាយហួសពីសមត្ថភាពគ្រប់គ្រងរបស់ផលិតករ និងកែលំអថ្លៃទិញលក់នៅកសិដ្ឋានសម្រាប់ទាំងស្រូវប្រាំង និងស្រូវវស្សា។

ការវិភាគខ្សែចង្វាក់តម្លៃបង្ហាញថា ស្រូវនៅខេត្តតាកែវមិនទាន់បំពេញបានតាមស្តង់ដារសម្រាប់នាំចេញទេ។ សកម្មភាពផ្សេងៗដែលគួរពិចារណាសម្រាប់ផ្នែកផលិតកម្មរួមមាន ការណែនាំឲ្យប្រើពូជស្រូវមានគុណភាពល្អ ការចែកចាយនិងផ្លាស់ប្តូរគ្រាប់ពូជជាថ្មីឲ្យបានទៀងទាត់ និងការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មស្តីពី វិធីល្អៗក្នុងការដាំស្រូវ ដូចជា ការគ្រប់គ្រងបញ្ហាសត្វចង្រៃ និងការកែលំអគុណភាពដី និងការប្រើជី។ សកម្មភាពទាំងនេះអាចឲ្យកសិករកាត់បន្ថយចំណាយផ្សេងៗ ជាពិសេសទៅលើជី និងថ្នាំសម្លាប់សត្វចង្រៃ ព្រមទាំងទទួលបានទិន្នផលស្រូវកាន់តែខ្ពស់ និងមានគុណភាពស្របតាមស្តង់ដារនាំចេញ ដែលនឹងផ្តល់នូវថ្លៃទីផ្សារកាន់តែប្រសើរ។

ទីផ្សារស្រូវមានរចនាសម្ព័ន្ធល្អនៅខេត្តតាកែវ ជួយឲ្យកសិករអាចលក់ស្រូវបានតាមតម្លៃទីផ្សារប្រកួតប្រជែង។ អតិរេកស្រូវគេអាចកិនវា និងលក់ដូរវាប្រកបដោយប្រសិទ្ធភាពនៅក្នុងទីផ្សារមូលដ្ឋាន ប៉ុន្តែសមត្ថភាពកិនស្រូវកម្រិតទាប និងកង្វះវិនិយោគជាមូលធន ធ្វើឲ្យផ្នែកកិនស្រូវនេះមិនអាចកែច្នៃអតិរេកស្រូវទាំងអស់បានទេ។ ដូច្នេះការនាំចេញស្រូវនៅតែសំខាន់បំផុត ប៉ុន្តែនាបច្ចុប្បន្ន អតិរេកស្រូវត្រូវបានដោះដូរតែជាមួយប្រទេសវៀតណាមប៉ុណ្ណោះ។ កម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយប្រទេសវៀតណាម ដើម្បីនាំចេញ និងនាំចូលស្រូវ ប៉ុន្តែការផ្លាស់ប្តូរក្នុងគោលនយោបាយពាណិជ្ជកម្មស្រូវអង្ករបស់វៀតណាម តាមរយៈការយកពន្ធគយកាន់តែច្រើន ការកំណត់កូតា ឬការបិទព្រំដែនដើម្បីការពារទីផ្សារក្នុងស្រុក អាចធ្វើឲ្យវិស័យស្រូវនៅខេត្តតាកែវ ជួបនឹងវិបត្តិ។ វិធានការសុវត្ថិភាពសេដ្ឋកិច្ចដ៏សំខាន់មួយ សម្រាប់ទប់ទល់នឹងហានិភ័យនៃការរអាក់រអួលបែបនេះ គឺការបើកដំណើរការនូវខ្សែចង្វាក់នាំចេញស្រូវរបស់កម្ពុជាមួយឡើង៕

ឯកសារយោងមាននៅក្នុងអត្ថបទជាអង់គ្លេស

*តពីទំព័រ ៤* **កំណែទម្រង់វិស័យជលផល...**

ទៅតាមតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន ហើយវាអាចបង្កើតឲ្យមានភាពតានតឹងរវាងសហគមន៍ នឹងអង្គភាពប្រតិបត្តិច្បាប់។ ប៉ុន្តែភាពយឺតយ៉ាវពេកក្នុងការសម្រេចចិត្ត ឬដាក់អនុវត្តច្បាប់ថ្មីៗ ក៏អាចបង្កជាបញ្ហាផងដែរ។ ដូច្នេះ ការស្វែងរកផ្លូវកណ្តាល ដើម្បីសម្រេចបានទាំងការចូលរួមប្រកបដោយប្រសិទ្ធភាព និងការអនុវត្តទាន់ពេលវេលានោះ មិនមែនជាការងាយស្រួលឡើយ។

ឯកឧត្តមអគ្គនាយកប្រធានរដ្ឋបាលជលផល បានបញ្ជាក់នៅក្នុងវេទិកាអង្គសិក្ខាសាលានោះថា ការអនុវត្តកំណែទម្រង់វិស័យជលផលបាន និងកំពុងជួបប្រទះបញ្ហាប្រឈមជាបន្តបន្ទាប់ ដូច្នេះ ត្រូវមានការប្រាស្រ័យទាក់ទងគ្នាជាចាំបាច់ រវាងតួអង្គពាក់ព័ន្ធទាំងអស់ និងត្រូវមានឆន្ទៈក្នុងការពិសោធន៍សាកល្បង និងរៀនសូត្ររួមគ្នា។ ការប្តេជ្ញាចិត្តធ្វើការពិសោធន៍សាកល្បង និងរៀនសូត្ររួមគ្នា ត្រូវមានដំណើរការអនុវត្តន៍នូវគំនិតឆ្នៃប្រឌិតថ្មីៗថែមទៀត ដើម្បីបំផុសគំនិតបែបថ្មីនៅថ្នាក់មូលដ្ឋាន ចងក្រងមេរៀនបទពិសោធន៍ដែលរៀនសូត្របាន ហើយយកទៅប្រើប្រាស់ ក្នុងកិច្ចខំប្រឹងប្រែងធ្វើកំណែទម្រង់ស្ថាប័ន និងគោលនយោបាយដែលទាក់ទងទៅនឹងវិស័យជលផលនាពេលអនាគត។ ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ និងភ្នាក់ងារជលផលនៅតាមមូលដ្ឋាន ក៏ត្រូវមានសមត្ថភាពនិងចំណេះដឹងថ្មីៗបន្ថែមទៀត ដើម្បីជួយទ្រទ្រង់ដល់ការអនុវត្តវិធីសាស្ត្រនេះ។

បឹងទន្លេសាបជាប្រព័ន្ធអេកូឡូស៊ីមួយដ៏ធំទូលាយ មានលក្ខណៈស្មុគស្មាញ និងងាយខ្ទេចខ្ទាំ។ ប្រព័ន្ធនេះបានជួយទ្រទ្រង់ដល់

*តទៅទំព័រ ១៨*